ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យរដ្ឋបាល
មកដល់ថ្ងៃទី ២៥ ខែ ១១ ឆ្នាំ ១០ ម៉ោង ៤ 
លេខ ២៧៩៤
អ្នកទទួល ... ហត្ថលេខា ...
អ្នកប្រគល់ ... ហត្ថលេខា ...
បញ្ជូនទៅ ...

25/11/10

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ: ០៧៤ សអយ

# សេចក្តីជូនដំណឹង

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានអនុគណៈកម្មការដោះស្រាយការងារបន្ទាន់លើករណីឧបទ្ទវហេតុនៅលើស្ពានពេជ្រនៃតំបន់កោះពេជ្រ សូមជម្រាបជូនបងប្អូនជនរួមជាតិឱ្យបានជ្រាបថា ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះទុក្ខលំបាករបស់ជនរងគ្រោះ ក្នុងឧបទ្ទវហេតុ នៅលើស្ពានពេជ្រ នៃតំបន់កោះពេជ្រ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំជាបន្ទាន់នៅរាត្រីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ ជាមួយថ្នាក់ដឹកនាំគណៈកម្មការដោះស្រាយការងារបន្ទាន់លើករណីឧបទ្ទវហេតុនៅលើស្ពានពេជ្រនៃតំបន់កោះពេជ្រ ជាមួយអាជ្ញាធររាជធានីភ្នំពេញ និងទំនាក់ទំនងតាមរយៈវីដេអូខុនហ្វឺរ៉េនផ្ទាល់ជាមួយអាជ្ញាធរខេត្តនានា ដើម្បីពិនិត្យដំណើរការសង្គ្រោះជនរងគ្រោះ និងការរៀបចំបញ្ជូនសាកសពជនរងគ្រោះទៅជូនគ្រួសារវិញ ក្នុងនោះបានពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់នូវស្ថានភាពជនរងគ្រោះ ។

រហូតដល់ម៉ោង ០០:៣០ នាទី ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១០ ការផ្ទៀងផ្ទាត់សម្រេចបានលទ្ធផលដូចតទៅ:

**១**-ចំនួនជនរងគ្រោះដែលបានទទួលមរណភាពសរុបចំនួន ៣៤៧ នាក់ ( ប្រុស ១២៦ ស្រី ២២១ នាក់) ។

-សពជនរងគ្រោះ បានចាត់ចែងបញ្ជូនទៅដល់លំនៅដ្ឋានរបស់ក្រុមគ្រួសារ និងបានចាត់ចែងពិធីបុណ្យតាមប្រពៃណី ដោយមានការជួយឧបត្ថម្ភ និងការចូលរួមពីថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ ។

-ចំនួនជនរងគ្រោះលើសបណ្តាលមកពីការរាប់ត្រួតគ្នានូវជនរងគ្រោះមួយចំនួន ដោយអាជ្ញាធររាជធានី និងខេត្ត មួយចំនួន ។

**២**-អ្នករងរបួសចំនួន ៣៩៥ នាក់ កំពុងសម្រាកនៅតាមមន្ទីរពេទ្យនានា និងទទួលបានការព្យាបាលពីមន្ទីរពេទ្យដោយឥតគិតថ្លៃ និងបានទទួលការឧបត្ថម្ភពីកាកបាទក្រហមកម្ពុជា និងសប្បុរសជនជាច្រើន ។

**៣**-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានអនុគណៈកម្មការដោះស្រាយការងារបន្ទាន់លើករណីឧបទ្ទវហេតុនៅលើស្ពានពេជ្រនៃតំបន់កោះពេជ្រ សូមកែតម្រូវសេចក្តីជូនដំណឹងលេខ ០៧៣ សអយ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១០ និងរបាយការណ៍លេខ ២៩៧៣ សអយ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមជនរួមជាតិ និងបណ្តាញផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាប និងកែតម្រូវតាមការគួរ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១០

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**និងជាប្រធានអនុគណៈកម្មការដោះស្រាយ**
**ការងារបន្ទាន់លើករណីឧបទ្ទវហេតុ**

**អ៊ិត សំហេង**